ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

តុលា ២០០៦ / October 2006

**ផាន់ ដាលីស / Phann Dalis**

**ប៉ុន ដូរីណា / Pon Dorina**

**ហ៊ីង វុត្ថា / Hing Vutha**

**ភីម រុនស៊ីណារិទ្ធិ / Phim Runsinarith**

បកប្រែដោយ: **យូ សិទ្ធីរិទ្ធ និង យេន សុផានី**

## ភ្នំពេញ កម្ពុជា

## Phnom Penh, Cambodia

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅខែមេសា-ឧសភា តំលៃវិនិយោគសរុបក្នុងវិស័យកាត់ដេរតិតជាទ្រព្យសកម្មជាប់លាប់ អនុម័តដោយ CDC មានត្រឹម ៣.១លានដុល្លារ រឺធ្លាក់ចុះ ៦៤% ធៀបនឹងកំឡុងពេលដូចគ្នា ឆ្នាំ២០០៥ ។ តំលៃវិនិយោគសរុប ថយចុះអស់ ៧៨% ធៀបនឹងខែកុម្ភៈ-មីនា ។

In April-May 2006, the total value of fixed asset investment approvals by the CDC for the garment sector was USD3.1 m, a 64 percent decrease compared to the same period in 2005. The total value of investment approvals declined by 78 percent compared to February-March.

**Fixed Asset Investments Approvals by CDC for Garment Sector 2003 Q2–2006 Q2***




** Up to May 2006.*
*Including expansion projects.*
Source: Council for the Development of Cambodia

នៅខែកក្កដា ភ្ញៀវបរទេសសរុប ១២៥.៣៩២នាក់ បានមកដល់កម្ពុជា ក្នុងនេះ ៨៩% ជាភ្ញៀវមកសំរាកលំហែ ។ ធៀបនឹងខែមិថុនា ភ្ញៀវមកសំរាកលំហែ កើន ១៨% ដល់ ១០៨.១១៨នាក់ ។ តួលេខនេះបង្ហាញផងដែរពីកំណើន ១២% នៃភ្ញៀវមកសំរាកលំហែ ធៀបនឹងខែកក្កដា ២០០៥ ។

A total of 125,392 foreign visitors arrived in Cambodia in July, 89 percent of whom were holiday visitors. Compared to June, holiday visitors increased by 18 percent to 108,118; this represented a rise of 12 percent in the number of holiday visitors over arrivals in July 2005.

**Foreign Visitor Arrivals by International Flights May 2005–July 2006**




Source: Ministry of Tourism

តំលៃគំរោងសាងសង់បានអនុម័តនៅភ្នំពេញ កើនដល់ ៤៤.៩លានដុល្លារ នៅខែកក្កដា រឺកើន ៥៣% ធៀបនឹងខែមុន ។ តំលៃគំរោងភូមិគ្រឹះ និងផ្ទះបានអនុម័ត ធ្លាក់ចុះ ៣.៧% មកត្រឹម ២.៦លានដុល្លារ ប៉ុន្តែ គំរោងផ្ទះល្វែង បែរជាកើន ៦២% ដល់ ៣៣.៦លានដុល្លារ ហើយ គំរោងសំណង់ផ្សេងទៀត កើនបាន ៥០% ដល់ ៨.៧លានដុល្លារ ។ ធៀបនឹងខែដូចគ្នាឆ្នាំមុន តំលៃគំរោងសាងសង់បានអនុម័ត កើន ៣៨% ។

The value of construction approvals in Phnom Penh increased to USD44.9 m in July, 53 percent more than in the previous month. The value of villa and house construction approvals declined by 3.7 percent to USD2.6 m, while flat approvals rose by 62 percent to USD33.6 m and other construction by 50 percent to USD8.7 m. The value of construction approvals increased by 38 percent from the same month last year.

**Value of Construction Approvals: Phnom Penh May 2005–July 2006**




Source: Phnom Penh municipality

# ថ្លៃទំនិញ និង អត្រាការប្រាក់លើប្រាក់បញ្ញើ

# Prices and Deposit Rates

នៅខែសីហា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញកើន ១,២% ធៀបនឹងខែកក្កដា ។ សន្ទស្សន៍ថ្លៃម្ហូបអាហារ និង ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍កើន ២,១% និង ១,០% ។ ធៀបនឹងខែសីហា ២០០៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើន ៥,១% ក្នុងនេះ ថ្លៃម្ហូបអាហារ កើន ៦,១% ហើយថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ១០,៥% ។

The consumer price index in Phnom Penh in August rose by 1.2 percent, compared to July. The price indices of food and of transportation and communication increased by 2.1 percent and 1.0 percent, respectively. Compared to August 2005, the CPI was up 5.1 percent. Food prices increased by 6.1 percent, transportation and communication by 10.5 percent.

**Consumer Price Index**

(July–December 2000=100)




Source: National Institute of Statistics

នៅខែកញ្ញា ថ្លៃជាមធ្យមនៃសាំង និងម៉ាស៊ូតនៅទីផ្សារ មានស្ថិរភាពដោយលក់ថ្លៃ ៤១៧៨រៀល/លីត្រ និង ៣៣៧៥រៀល/លីត្រ ។ ធៀបនឹងខែកញ្ញា ២០០៥ សាំងឡើងថ្លៃ ១២% ហើយម៉ាស៊ូតឡើងថ្លៃ ១៦% ។

In September, the average market prices of gasoline and diesel in Phnom Penh were stable at 4,178 riels and 3,375 riels/litre, respectively. Compared to September 2005, gasoline was up by 12 percent and diesel by 16 percent.

**Gasoline and Diesel Prices: Phnom Penh**
**July 2005–September 2006**




Sources: CDRI and National Institute of Statistics

នៅខែកក្កដា ២០០៦ អត្រាការប្រាក់សំរាប់បញ្ញើជាប្រាក់រៀល ផ្តល់ដោយធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) គឺ ៦,៥% ធៀបនឹង ៦% របស់ធនាគារកាណាឌីយ៉ា និង ៨,០% របស់ អេស៊ីលីដា ។ សំរាប់ប្រាក់បញ្ញើជាដុល្លារ FTB និងកាណាឌីយ៉ា ផ្តល់ការប្រាក់ ៥,០% ហើយអេស៊ីលីដាផ្តល់រហូតដល់ទៅ ៦,០% ។

In July 2006, the interest rate on 12-month riel deposits offered by the Foreign Trade Bank (FTB) was 6.5 percent, compared to 6.0 percent by Canadia Bank and 8.0 percent by ACLEDA Bank. On dollar deposits, the FTB and Canadia offered 5.0 percent, and ACLEDA 6.0 percent.

**Interest Rates on 12-Month Bank Deposits**

(As of July 2006)




Source: National Bank of Cambodia

# អត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែកញ្ញា ប្រាក់រៀលបន្តធ្លាក់ថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ៤១៧៣រៀល/ដុល្លារ ធៀបនឹង ៤១៣៩រៀល/ដុល្លារ នៅខែមុន ។ ធៀបនឹងខែកញ្ញា ឆ្នាំមុន ប្រាក់រៀលឡើងថ្លៃ ០,៨% ។

In September, the riel continued to depreciate against the US dollar, trading at 4173, compared with 4139 riels/dollar in the previous month. Compared to September last year, the riel had appreciated by 0.8 percent.

**Riels per US Dollar**
**July 2005 – September 2006**




Sources: National Bank of Cambodia and CDRI

អត្រាប្តូរប្រាក់រវាងប្រាក់រៀល និងប្រាក់បាតថៃ នៅខែកញ្ញា គឺ ១១២រៀល/បាត រឺថយចុះ ១,៨% ធៀបនឹង ១១០រៀល/បាតនៅខែមុន។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលនៅថេរ ដោយប្តូរបាន ២៥រៀល/ ១០០ដុង ប៉ុន្តែឡើងថ្លៃ ៣,៨% ធៀបនឹងខែកញ្ញាឆ្នាំមុន ។ ធៀបនឹង ២០០៥ (មករា-កញ្ញា) ប្រាក់រៀល ឡើងថ្លៃបាន ១,៦% ។

The exchange rate of the riel with the Thai baht in September was 112 KHR/THB, a depreciation of 1.8 percent from 110 KHR/THB in the preceding month. Against the Vietnamese dong, the riel was stable at 25 riels per 100 dong, a 3.8 percent appreciation compared to September last year. Compared to 2005 (January-September) the riel appreciated by 1.6 percent.

**Riels per THB and VND**
**July 2005–September 2006**




Source: CDRI

នៅឆ្នាំ១៩៩៦-២០០៥ វិស័យអភិវឌ្ឍន៍នៅកម្ពុជា ដូចជា ការអភិវឌ្ឍន៍ជនបទ ការអភិវឌ្ឍន៍ភូមិ/សហគមន៍ ការអភិវឌ្ឍន៍អាងទន្លេ ទីជំរក ការអភិវឌ្ឍន៍តំបន់អន្តរប្រទេស និង ការធ្វើផែនការនិងការអភិវឌ្ឍន៍តំបន់ បានទទួលជំនួយ ៥៨៨,៥លានដុល្លារ រឺ ១២%នៃជំនួយអភិវឌ្ឍន៍បរទេស។ នៅឆ្នាំ២០០៥ មានការបើកផ្តល់ ៤៥,៥លានដុល្លារទៅឱ្យវិស័យនេះ រឺ ២៥%តិចជាងការបើកផ្តល់នៅឆ្នាំ២០០៤ ។ អ្នកផ្តល់ជំនួយសំខាន់ៗនៅឆ្នាំ ២០០៥ មាន ជប៉ុន ADB អង់គ្លេស អាឡឺម៉ង់ និងអូស្ត្រាលី ។

Cambodia’s area development sector—integrated rural development, village/community development, river basin development, settlements, intercountry area development, and regional planning and development—received USD588.5 m, 12 percent of external development assistance, during 1996–2005. In 2005, USD45.5 m was disbursed in this sector, a 25 percent fall from 2004. The main disbursement providers for this sector in 2005 were Japan, ADB, UK, Germany and Australia.

**External Development Assistance: Disbursement for Area Development 1996-2005**




Source: Council for the Development of Cambodia

# ការវិវត្តន៍រូបិយវត្ថុ និង អត្រាការប្រាក់លើកំចី

# Monetary Developments and Loan Rates

នៅខែកក្កដា រូបិយវត្ថុទូទៅ M2 កើនឡើងតាមអត្រាប្រចាំឆ្នាំ ៣២% ហើយ និងការផ្គត់ផ្គង់រូបិយវត្ថុ M1 កើន ៩.១% ។ ក្នុងរយៈ១២ខែ រូបិយវត្ថុទូទៅ M2 កើនបាន ២៩% ធៀបនឹងអត្រាកំណើន ៣១% នៅក្នុងរយៈមួយឆ្នាំដល់ខែមិថុនា ២០០៦ ។

In July, liquidity (M2) grew at an annualised rate of 32 percent, and money supply (M1) at 9.1 percent. Over the previous 12 months, liquidity grew by 29 percent, compared to a growth rate of 31 percent in the year to June 2006.

**Monetary Survey**
**August 2005–July 2006**




Source: National Bank of Cambodia

នៅខែកក្កដា ឥណទានក្នុងស្រុក កើនតាមអត្រាប្រចាំឆ្នាំ ៣៩% ហើយឥណទានសំរាប់វិស័យឯកជន កើនតាមអត្រាប្រចាំឆ្នាំ ៥១% ។ ក្នុងរយៈ១២ខែដល់ខែកក្កដា ២០០៦ ឥណទានក្នុងស្រុក កើន ១៦% ធៀបនឹងកំណើន ១៩% ក្នុងរយៈមួយឆ្នាំឆ្នាំដល់ខែមិថុនា ២០០៦ ។

In July, domestic credit grew at an annualised rate of 39 percent, while private sector credit grew at an annualised rate of 51 percent. Over the twelve months to July 2006, domestic credit grew by 16 percent, compared to a growth rate of 19 percent in the year to June 2006.

**Domestic Credit**
**July 2005–July 2006**




Source: National Bank of Cambodia

នៅខែកក្កដា ២០០៦ អត្រាការប្រាក់លើកំចីជារៀលរយៈ១២ខែ អនុវត្តដោយធនាគារពាណិជ្ជកម្មក្រៅប្រទេស FTB គឺ ១៨% ធៀបនឹង ២៤% អនុវត្តដោយធនាគារ កាណាឌីយ៉ា និងអេស៊ីលីដា ។ សំរាប់កំចីជាដុល្លារ FTB កាណាឌីយ៉ា និងអេស៊ីលីដា អនុវត្តអត្រាការប្រាក់ដូចគ្នា គឺ ១៨% ក្នុងមួយឆ្នាំ។

As of July 2006, the interest rate on 12-month riel loans offered by the Foreign Trade Bank (FTB) was 18 percent, compared to 24 percent by Canadia Bank and ACLEDA Bank. For dollar loans, the FTB, Canadia and ACLEDA offered the same rate, 18 percent per year.

**Interest Rates on 12-Month Loans**
(As of July 2006)




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

នៅខែកក្កដា តំលៃទំនិញនាំចេញសរុបរបស់កម្ពុជា គឺ ២៦១.២លានដុល្លារ រឺ ១៤% តិចជាងនៅខែមុន ។ ការនាំចេញសំលៀកបំពាក់ ធ្លាក់ចុះអស់ ១៥% មកត្រឹម ២៥១.៨លានដុល្លារ ប៉ុន្តែការនាំចេញកៅស៊ូ និងត្រី កើនបាន ៥០% ដល់ ៥.១លានដុល្លារ និង ៦៧% ដល់ ០.៥លានដុល្លារ ។ ការនាំចេញសរុប កើនបាន ២.៤% បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។

The total value of goods exports from Cambodia in July was USD261.2 m, 14 percent less than a month earlier. Garment exports declined by 15 percent to USD251.8 m, while rubber and fish exports increased by 50 percent to USD5.1 m and 67 percent to USD0.5 m, respectively. However, exports were up by 2.4 percent from the same month last year.

**Cambodia: Main Exports**
**May 2005-July 2006**




Source: Customs and Excise Department

នៅខែកក្កដា ការនាំចូលសំភារៈសំណង់ជា ស៊ីម៉ង់ត៍ និងដែក មានតំលៃសរុប ៣០.៨ពាន់លានរៀល ក្នុងនេះការនាំចូលដែក មាន ៥៤% ។ ការនាំចូលបារី មាន ៣៨.២ពាន់លានរៀល ។ ធៀបនឹងខែមុន ការនាំចូលសំភារៈសំណង់ធ្លាក់ចុះ ៣.១% ក្នុងនេះស៊ីម៉ង់ត៍ ធ្លាក់ចុះ ២៨% ប៉ុន្តែដែក កើន ៣៨% ។ ការនាំចូលបារី ថយចុះ ២២% ធៀបនឹងកំរិត ៤៨.៧ពាន់លានរៀល នៅខែមិថុនា ។

In July, the total value of construction material imports, cement and steel, was KHR30.8 bn, of which steel imports made up 54 percent. Cigarette imports were KHR38.2 bn. Compared to the preceding month, imports of construction materials were down by 3.1 percent, cement falling by 28 percent, while steel rose 38 percent. Imports of cigarettes decreased by 22 percent, from KHR48.7 bn in June.

**Imports: Cigarettes & Construction Materials**
**May 2005–July 2006**




Source: Customs and Excise Department

កម្ពុជានាំចូលប្រេងសាំងសរុប ១៤.៨០០តោន (១៨.៨ពាន់លានរៀល) និងម៉ាស៊ូត ៤៥.០០០តោន (៣៦.៨ពាន់លានរៀល) នៅខែកក្កដា ។ បរិមាណម៉ាស៊ូតនាំចូល កើន ៣៨% ធៀបនឹងខែមុន ប៉ុន្តែបរិមាណសាំងនាំចូល បានថយចុះ ២.០% ។ ទោះយ៉ាងនេះក្តី ការនាំចូលផលិតផលទាំងពីរ កើនឡើង បើធៀបនឹងខែដូចគ្នាឆ្នាំមុន ដោយសាំងកើន ៤១% ហើយម៉ាស៊ូតកើន ២០% ។

Cambodia imported a total of 14,800 tonnes of gasoline (costing KHR18.8 bn) and 45,000 tonnes of diesel (KHR36.8 bn) in July. The volume of diesel imports increased by 38 percent from the previous month, while gasoline imports decreased by 2.0 percent. However, imports of both were higher than in the same month last year, gasoline by 41 percent and diesel by 20 percent.

**Imports: Petroleum Product**
**May 2005–July 2006**




Source: Customs and Excise Department

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

ឱនភាពថវិកាចរន្តរបស់រដ្ឋាភិបាល មានទំហំ ៣១ពាន់លានរៀល នៅខែឧសភា ២០០៦ ធៀបនឹងអតិរេកថវិកា ៦២ពាន់លានរៀលនៅខែមុន ។ រឿងនេះបង្ហាញពីកំណើន ៨៣% នៃចំណាយចរន្ត ។

The government's current budget deficit was KHR31 bn in May 2006, compared to a surplus of KHR62 bn in the previous month. This reflected an increase of 83 percent in current expenditure.

**Current Budget Operations**
**March 2005–May 2006**




*Note: Provisional for2006.*
Source: *Monthly Bulletin of Statistics* (MEF)

រដ្ឋាភិបាលមានចំណូលចរន្ត ២៣២.២ពាន់លានរៀល នៅខែឧសភា ដោយកើនបាន ១៣% ធៀបនឹងកំរិត ២០៥.៣ពាន់លានរៀល នៅខែមេសា ។ ចំណូលមិនមែនពន្ធ កើន ៧.៤% ដល់ ៤២.០ពាន់លានរៀល, ពន្ធក្នុងស្រុក កើន ១៤% ដល់ ៦៤.១ពាន់លានរៀល ហើយពន្ធនាំចេញនាំចូល កើន ១៥% ដល់ ១២៦.១ពាន់លានរៀល ។

Government current revenue amounted to KHR232.2 bn in May, a rise of 13 percent, from KHR205.3 bn, in April. Non-tax revenue increased by 7.4 percent to KHR42.0 bn, domestic taxes by 14 percent to KHR64.1 bn and import and export taxes by 15 percent to KHR 126.1 bn.

**Current Budget Revenue**
**March 2005–May 2006**




*Note: Provisional for 2006.*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែឧសភា ចំណាយចរន្តកើនដល់ ២៦២.៨ពាន់លានរៀល រឺកើន ៨៣% ធៀបនឹងខែមេសា ។ ចំណាយលើរដ្ឋបាលសង្គម មាន ១១៣.៦ពាន់លានរៀល ធៀបនឹង ១០៩.៩ពាន់លានរៀល នៅខែមុន ។ ចំណាយលើរដ្ឋបាលទូទៅកើន ១២% ដល់ ៣៤.៧ពាន់លានរៀល ។ ចំណាយលើសន្តិសុខ និងការពារជាតិ កើនពី ២៦.១ពាន់លានរៀល ដល់ ៦៣.៨ពាន់លានរៀល ហើយចំណាយលើរដ្ឋបាលសេដ្ឋកិច្ច កើនជិតទ្វេដង ដល់ ២៧.៦ពាន់លានរៀល ។

In May, current expenditure rose by 83 percent from April, to KHR262.8 bn. Expenditure on social administration was KHR113.6 bn, compared with KHR 109.9 bn in the preceding month. General administration increased by 12 percent to KHR34.7 bn. Expenditure on defence and security expanded from KHR26.1 bn to KHR 63.8bn, while economic administration outlays nearly doubled to KHR27.6 bn.

**Current Budget Expenditure**
**March 2005–May 2006**




*Note: Provisional for 2006.*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែកក្កដា ការនាំចេញទំនិញរបស់ US តំបន់អឺរ៉ូ និងជប៉ុន មានការធ្លាក់ចុះបន្តិចបន្តួច ។ ការនាំចេញរបស់ US ធ្លាក់ចុះពី ៨៦,៥៧ពាន់លានដុល្លារ នៅខែមិថុនា មកត្រឹម ៨៥,៦៥ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់តំបន់អឺរ៉ូ ធ្លាក់ចុះអស់ ៣,២% ធៀបនឹងខែមុន មកត្រឹម ១៤០,១៣ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់ជប៉ុន ក៏ធ្លាក់ចុះដែរ ពី ៥៥,៦៤ពាន់លានដុល្លារ មកត្រឹម ៥៤,៨១ពាន់លានដុល្លារ ។

In July, goods exports of the US, the Euro zone and Japan decreased marginally. US exports went down from USD86.57 bn in June to USD85.65 bn. Euro zone goods exports decreased by 3.2 percent from the previous month to USD140.13 bn. Japan's goods exports decreased from USD55.64 bn to USD 54.81 bn.

## Goods Exports: US, Euro zone and Japan




Sources: BEA, Eurostat and OECD

នៅខែកក្កដា ការនាំចេញទំនិញរបស់តៃវ៉ាន់ មាន ១៩,៥៨ពាន់លានដុល្លារ រឺកើន ៨,២% ធៀបនឹងខែមុន និងកើន ២១% ធៀបនឹងខែកក្កដា ឆ្នាំមុន ។ ក្នុងនេះការនាំចេញផលិតផលកសិកម្ម កើន ១៨% ធៀបនឹងខែមុន ហើយ ការនាំចេញផលិតផលកសិកម្មកែច្នៃ និងផលិតផលឧស្សាហកម្ម កើន ១២% និង ៨,២% ។ ទិន្នន័យនៃការនាំចេញទំនិញរបស់កូរ៉េខាងត្បូង មិនទាន់មានទេ សំរាប់ខែកក្កដា ។

In July, Taiwan's goods exports were USD19.58 bn, an increase of 8.2 percent from the previous month and 21 percent from July last year. Exports of agricultural products increased by 18 percent from the previous month, while exports of processed agricultural products and industrial products increased by 12 percent and 8.2 percent respectively. Goods export data for South Korea are not yet available for July.

## Goods Exports: South Korea and Taiwan




Sources: National statistics department of each country

នៅខែកក្កដា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ២,៣៩ពាន់លានដុល្លារ ធៀបនឹងអតិរេក ២,២៦ពាន់លានដុល្លារ នៅខែមិថុនា ។ ការនាំចេញសរុប កើន ២,0% ដល់ ១៣,៣១ពាន់លានដុល្លារ ឯការនាំចូលសរុបកើន ១,២% ដល់ ១០,៩២ពាន់លានដុល្លារ ។ ផលិតផលអគ្គិសនី និងអេឡិចត្រូនិក មានចំនួន ៦,៣១ពាន់លានដុល្លារ រឺស្មើនឹង ៤៧% នៃ ការនាំចេញសរុប ។

In July, Malaysia recorded a trade surplus of USD2.39 bn, compared to USD2.26 bn in June. Total exports rose by 2.0 percent to USD13.31 bn, while total imports increased by 1.2 percent to USD10.92 bn. Electrical and electronic products accounted for USD6.31 bn, 47 percent of total exports.

## Malaysia: External Trade




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅ US កើនឡើង ៤.១% ក្នុងរយៈមួយឆ្នាំគិតដល់ខែកក្កដា ។ យោងតាម នាយកដ្ឋានពលកម្មរបស់ US កំណើននេះបណ្តាលមកពី ការឡើងថ្លៃថាមពល ផ្ទះស្នាក់នៅ និងការដឹកជញ្ជូន ។ នៅកំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់ កើន ២.២% នៅតំបន់អឺរ៉ូ និងកើន ០.៣% នៅជប៉ុន ។

US consumer prices rose by 4.1 percent in the year to July. According to the US Department of Labour, the increases were due to higher costs of energy, housing and transportation. During the same period, consumer prices rose by 2.2 percent in the Euro zone and 0.3 percent in Japan.

**Inflation Rate: US, Euro zone & Japan**
(change from one year earlier)




*Note: The latest data available are for July 2006.*
Sources: IMF and *Economist* (16 September 2006)

នៅខែកក្កដា ថ្លៃទំនិញប្រើប្រាស់នៅហុងកុងកើន ២.៣% ធៀបនឹងកាលពីមួយឆ្នាំមុន គឺខ្ពស់ជាងកំនើន ២.២% ក្នុងរយៈមួយឆ្នាំគិតដល់ខែមិថុនា ។ កំណើនបន្តិចបន្តួចនេះ បណ្តាលជាសំខាន់មកពី កំណើនថ្លៃខ្សែទស្សនកិច្ច និងថាមពល ។ ក្នុងកំឡុងពេលដូចគ្នា អតិផរណាថ្លៃទំនិញប្រើប្រាស់នៅចិន និងកូរ៉េខាងត្បូង គឺ ១.៣% និង ២.៣% ។

Hong Kong consumer prices rose by 2.3 percent in July over a year earlier, more than the 2.2 percent increase in the year to June. The slightly larger increase was mainly attributable to package tour charges and energy costs. During the same period, consumer inflation in China and South Korea was 1.3 percent and 2.3 percent, respectively.

**Inflation Rate: China, Hong Kong & South Korea**
(change from one year earlier)




*Note: The latest data available are for July 2006.*
Sources: IMF and *Economist* (16 September 2006)

នៅខែកក្កដា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើន ១.១% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី កំណើននេះបណ្តាលមកពី ការឡើងថ្លៃម្ហូបអាហារ សំលៀកបំពាក់ ស្បែកជើង ផ្ទះស្នាក់នៅ ការអប់រំ និងសំភារៈការិយាល័យ ។ អត្រាអតិផរណាក្នុងរយៈមួយឆ្នាំ គឺ ៤.១% នៅម៉ាឡេស៊ី និង ៤.៤% នៅថៃ ។

Singapore's consumer price index in July was 1.1 percent higher than in the same month a year earlier. According to the Department of Statistics of Singapore, this reflected higher costs for food, clothing and footwear, housing, education and stationery. The year-on-year inflation rate was 4.1 percent in Malaysia and 4.4 percent in Thailand.

**Inflation Rate: Selected ASEAN Countries**
(change from one year earlier)




*Note: The latest data available are for July 2006.*
Sources: IMF and *Economist* (16 September 2006)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែកញ្ញា ដុល្លារUS ឡើងថ្លៃទល់នឹងរូបិយវត្ថុចំបងៗ ។ វាប្តូរបាន ១១៧,២យ៉េន/ដុល្លារUS រឺឡើងថ្លៃ ១,១% ធៀបនឹងខែសីហា ហើយទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៧៩អឺរ៉ូ/ដុល្លារUS រឺឡើងថ្លៃ ០,៧% ធៀបនឹងខែមុន ។

In September, the US dollar advanced against most major currencies. It bought 117.2 Japanese yen, 1.1 percent more than in August, and 0.79 euros, a 0.7 percent gain from the preceding month.

**EUR & JPY Against USD**

Sept 05–Sept 06 (Monthly average)




Source: Federal Reserve Bank of New York

នៅខែកញ្ញា ប្រាក់វ៉ុនកូរ៉េខាងត្បូង ឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៩៥២,៦៧វ៉ុន/ដុល្លារUS ធៀបនឹង ៩៦០,៩៥វ៉ុន/ដុល្លារUS នៅខែមុន ។ ដុល្លារហុងកុង មានថ្លៃថេរទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៧៨ ដុល្លារហុងកុង/ដុល្លារUS ។

In September, the South Korean won appreciated slightly against the US dollar, trading at 952.67 KRW/USD, compared to 960.95 KRW/USD a month earlier. The Hong Kong dollar remained flat against its US counterpart, trading at 7.78 HKD/USD.

**KRW & HKD Against USD**

Sept 05-Sept 06 (Monthly average)




Source: Federal Reserve Bank of New York

នៅខែកញ្ញា ដុល្លារសិង្ហបុរី ប្តូរបាន ១,៥៨០ដុល្លារសិង្ហបុរី/ដុល្លារUS រឺធ្លាក់ថ្លៃ ០,៣% ធៀបនឹងខែមុន ។ ប្រាក់បាតថៃ ប្តូរបាន ៣៧,៤៣បាត/ដុល្លារUS រឺឡើងថ្លៃ ០,៤% ធៀបនឹងខែសីហា។

In September, the Singapore dollar traded at 1.580 SGD/USD, a 0.3 percent depreciation from the previous month. The Thai baht strengthened to 37.43 THB/USD, a 0.4 appreciation from August.

**THB & SGD Against USD**

Sept 05-Sept 06 (Monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែសីហា ថ្លៃអង្ករនៅលើពិភពលោក កើនឡើង លើកលែងតែនៅថៃ ដែល អង្ករ Thai 100%B ធ្លាក់ថ្លៃដល់ ២៨៩,៣៣ដុល្លារ/តោន ធៀបនឹង ២៩២,៩៦ដុល្លារ/តោននៅខែកក្កដា ដោយសារតំរូវការនៅទីផ្សារបរទេសធ្លាក់ចុះ ។ សន្ទស្សន៍ថ្លៃអន្តរជាតិ នៅថេរត្រឹមកំរិត ១៣០,0ពិន្ទុ ។ នៅ US ថ្លៃអង្ករនាំចេញ កើនដល់ ៣៥១,0១ដុល្លារ/តោន ធៀបនឹង ៣៤៣,៧៥ដុល្លារ/តោន នៅខែកក្កដា ។

In August, world rice prices increased, except in Thailand, where the price of Thai 100%B fell to USD289.33 per tonne from USD292.96 in July because of a slow external market. The international price index (IPO) remained stable at 130.0. In the United States, the export price increased to USD351.01 per tonne, against USD343.75 in July.

**International Prices Index and Export Rice Prices**
(USD/tonne FOB)




Sources: Osiriz/InfoArroz and InterRice.

នៅខែកញ្ញា សណ្តែកសៀង ធ្លាក់ថ្លៃ ប៉ុន្តែពោត និងប្រេងឆា បែរជាឡើងថ្លៃ ។ សណ្តែកសៀង លក់ថ្លៃ ២0២,៣៤ដុល្លារ/តោន ដោយធ្លាក់ថ្លៃពី ២0៣,១0ដុល្លារ/តោន នៅខែសីហា ។ ពោត លក់ថ្លៃ ១0៨,២១ដុល្លារ/តោន ធៀបនឹង ១0៣,៧0ដុល្លារ/តោន នៅខែសីហា ។ នៅខែសីហា ប្រេងឆាឡើងថ្លៃបាន ៨,៣% ធៀបនឹង ៤៦២,៥៧ដុល្លារ/តោន នៅខែកក្កដា ។

The price of soybeans declined in September, while the prices of maize and palm oil increased. Soybeans sold at USD202.34 per tonne, down from USD203.10 in August. Maize was USD108.21 per tonne, up from USD103.70 in August. In August, palm oil rose by 8.3 percent from July, to USD462.57 per tonne.

**International Prices of Soybeans, Maize and Palm Oil**
(USD/tonne FOB)




Source: Food and Agriculture Organisation (FAO)

នៅខែកញ្ញា ថ្លៃប្រេងឆៅ សាំង និងម៉ាស៊ូត ធ្លាក់ចុះ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៦១,៦៤ដុល្លារ/ធុង ធៀបនឹង ៧0,៣៣ដុល្លារ/ធុង នៅខែសីហា ។ ប្រេងសាំងធម្មតា (អុកតាន ៨៧) នៅ US Gulf Coast ចុះថ្លៃដល់ ៤២,៥៦សេន/លីត្រ រឺចុះថ្លៃ ២៤% ធៀបនឹងកំរិត ៥៥,៩៧សេន/លីត្រ នៅខែសីហា ។ ប្រេងឆៅ (មានលាយស្ពាន់ធ័រតិចលេខ ២) ក៏ចុះថ្លៃដែរ គឺចុះអស់ ១៨% ធៀបនឹងខែមុន មកត្រឹម ៤៨,៧0សេន/លីត្រ ។

In September, the prices of crude oil, gasoline and diesel decreased. The OPEC spot price of crude oil was USD61.64 per barrel, against USD70.33 in August. Regular gasoline (87 octane) prices on the US Gulf Coast decreased by 24 percent, to 42.56 cents per litre compared to 55.97 cents per litre in August. The diesel price (low sulphur No.2) on the US Gulf Coast also declined significantly, by 18 percent from the previous month, to 48.70 cents per litre.

**Prices of Crude Oil, Gasoline and Diesel**




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**កម្ពុជាអនុញ្ញាតឱ្យក្រុមហ៊ុនរុស្ស៊ីអភិវឌ្ឍកោះទៅជារមនីយដ្ឋានទេសចរណ៍:** រដ្ឋាភិបាលកម្ពុជាបានយល់ព្រមឱ្យ ក្រុមហ៊ុនរុស្ស៊ីអភិវឌ្ឍកោះសមុទ្រមួយ ទៅជារមនីយដ្ឋានទេសចរណ៍ ដោយមានទឹកប្រាក់វិនិយោគដំបូងរហូតដល់ ៣០០លានដុល្លារ ។ កិច្ចព្រមព្រៀងនេះអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគ ឈ្មោះកោះពស់ អភិវឌ្ឍនិងគ្រប់គ្រងលើកោះពស់ ក្នុងរយៈពេល ៩៩ឆ្នាំ បើតាមសំដីរបស់ Khiem Kolneath ជំនួយការរបស់ Alexander Trofimov ជាប្រធានក្រុមហ៊ុន ។ កោះពស់ ស្ថិតនៅប្រហែល ៨០០ម៉ែត្រ ពីឆ្នេរប្រជាប្រិយរបស់ក្រុងព្រះសីហនុ និងប្រហែល ១៨៥គ.ម ភាគនិរតី ក្រុងភ្នំពេញ ។ Khiem Kolneath បញ្ជាក់ថា ក្រុមហ៊ុនមានពេល ៦ខែ ដើម្បីបង្ហាញរដ្ឋាភិបាលពីផែនការមេសំរាប់ការអភិវឌ្ឍន៍ ដែលរួមមាន សណ្ឋាគារ មណ្ឌលលំហែកំសាន្ត និងស្ពានភ្ជាប់ពីឆ្នេរទៅកោះ ។ គាត់បញ្ជាក់ថែមថា ចំនុចលំអិតក្នុងផែនការមេ នឹងអាចប្រែប្រួលទៅតាម ការសើរើពិនិត្យ និងការអនុមតិរបស់រដ្ឋាភិបាល ។

***Cambodia allows Russian firm to develop island into a tourist resort:*** The Cambodian government has agreed to allow a Russian-run company to develop a coastal island into a tourist resort with an initial investment of up to US$300 million. The agreement will allow Koh Pos Investment Co. Ltd. to develop and manage Koh Pos, or Snake Island, for 99 years, said Khiem Kolneath, an assistant to Alexander Trofimov, the company's chairperson. The island is located about 800 metres off a popular beach in Sihanoukville, about 185 kilometres south-west of the capital, Phnom Penh. Khiem Kolneath said the company has six months to present the government with a development master plan, which will include a hotel, a recreation centre and a bridge linking the beach with the island. He added that details of the master plan will be subject to the government's review and approval. *(Cited from iht.com, 27 September 2006)*

**ចក្រភពអង់គ្លេសផ្តល់ជំនួយ ៧៥លានដុល្លារ ឱ្យកម្ពុជាក្នុងបីឆ្នាំខាងមុខ:** ចក្រភពអង់គ្លេសនឹងផ្តល់ជំនួយ ៧៥លានដុល្លារ ឱ្យកម្ពុជាក្នុង៣ឆ្នាំខាងមុខ ដើម្បីគាំទ្រដល់ការប្រយុទ្ធនឹងភាពក្រីក្រ និងរោគរាតត្បាត តាមសំដី លោក Mark Lowcock អគ្គនាយកនៃនាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ នៅពេល មកធ្វើទស្សនកិច្ច នាថ្ងៃ១៩ កញ្ញា ។ ការគាំទ្រនឹងផ្តោតលើ ការបង្កើន ប្រសិទ្ធភាពជំនួយ ការពង្រឹងអភិបាលកិច្ច ការកែលំអក៏រិតជីវភាពរបស់ ជនក្រីក្រ ការកែលំអសេវាសុខាភិបាល និងការប្រយុទ្ធនឹងជំងឺអេដស៍ ។ លោក Mark ប្រាប់ថា ជំនួយនេះនឹងត្រូវផ្តល់ស្របតាមគោលការណ៍ អភិបាលកិច្ចល្អ ដែលជាចំនុចស្នូលនៅក្នុងផែនការសកម្មភាពរបស់ចក្រភព អង់គ្លេស ដើម្បីប្រយុទ្ធនឹងភាពក្រីក្រនៅជុំវិញពិភពលោក ។ នៅក្នុងឱកាស ផ្សព្វផ្សាយពីរបាយការណ៍គោលនយោបាយ(សៀវភៅស)លើកទី៣ ស្តីពី ការអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស លោក Mark លើកថា ការរីកចំរើនក្នុងរយៈពេលវែងនៃការប្រយុទ្ធនឹងភាពក្រីក្រ អាចសំរេចទៅបាន តាមរយៈរដ្ឋាភិបាលមានប្រសិទ្ធភាពល្អ និងប្រជាជនដែលហ៊ានបញ្ចេញ មតិ និងមានទំនុកចិត្តក្នុងខ្លួនដើម្បីទាមទារគណនេយ្យភាពពីរដ្ឋាភិបាល ។ របាយការណ៍គោលនយោបាយដែលមានចំណងជើងថា "ការកាត់បន្ថយភាព ក្រីក្រក្នុងពិភពលោក: ការយកអភិបាលកិច្ចល្អមកជួយអ្នកក្រ" បានឆ្លើយ តបនឹងបញ្ហាប្រឈម៤ គឺ សារៈសំខាន់នៃអភិបាលកិច្ចល្អនៅប្រទេសក្រីក្រ, ការកែលំអសន្តិសុខ ការរីកចំរើន និងសេវាសាធារណៈដើម្បីកាត់បន្ថយភាព ក្រីក្រ, ការដោះស្រាយបំរែបំរួលអាកាសធាតុ, និងកំនែទំរង់ប្រព័ន្ធអន្តរជាតិ ដើម្បីកសាងប្រទេសនានាឱ្យកាន់តែមានប្រសិទ្ធភាព និងគណនេយ្យភាព ។

***UK to provide Cambodia with USD75 m in aid in next three years:*** The United Kingdom would provide Cambodia with USD75 m in the next three years to support the fight against poverty and epidemics, said Mark Lowcock, the visiting director general of the UK's Department for International Development on 19 September. The support will be focused on enhancing aid effectiveness, strengthening governance, improving the livelihoods of poor people, improving health services and tackling HIV/AIDS. The aid was given in line with the principle of good governance, which was at the centre of the UK's new action plan to fight world poverty, he said. "Long-term progress in the fight against poverty will only be achieved through effective government and by people with the voice and confidence to hold their government to account", said Lowcock at the launching of his government's third white paper on international development. The white paper, entitled "Eliminating world poverty: Making governance work for the poor", responded to four challenges: the importance of good governance in poor countries; the improvement of security, growth and public services to reduce poverty; the tackling of climate change; and the reform of the international system to build more effective and accountable states. *(Cited from Xinhua, 20 September 2006)*